ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

*****

PHNOM PENH
SPECIAL ECONOMIC ZONE
COMMITTED TO THE FUTURE

លេខ: ៥៨/២១-PPSEZ

# សេចក្តីជូនដំណឹង

## ស្តីពី

## កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញ របស់ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី

**ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី** មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធបោះឆ្នោតទាំងអស់មេត្តាជ្រាបថា កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញ នឹងប្រព្រឹត្តិទៅនៅថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០២២ ដោយអនុលោមតាមការយល់ព្រមរបស់ក្រុមប្រឹក្សាភិបាល របស់ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី កាលពីថ្ងៃទី០៣ ខែ មករា ឆ្នាំ ២០២២ ។

ការប្រជុំនេះនឹងត្រូវធ្វើឡើង ដោយមានការខលហៅជាវីដេអូ ដោយយោងទៅតាមគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាលក្នុងអំឡុងវិបត្តិកូវីដ ១៩ នៅក្នុងប្រទេសកម្ពុជា។ ដូច្នេះការរៀបចំកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកនេះមានការកំណត់ដូចខាងក្រោម:

១. កាលបរិច្ឆេទកំណត់ទុក (Recorded date): ថ្ងៃទី ០៦ ខែមករា ឆ្នាំ ២០២២

២. កាលបរិច្ឆេទកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក: ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០២២ វេលាម៉ោង ២:០០-៤:០០ រសៀល

៣. ទីកន្លែង: តាមរយៈការហៅជាវីដេអូ

៤. របៀបវារៈនៃកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក:

- បទបង្ហាញនៃសេចក្តីសម្រេចទី១: ការការអនុម័តលើការផ្ទេរភាគហ៊ុនពីលោកលោកជំទាវឧកញ៉ា លីម ឈីវហួរ ដែលមាននៅក្នុង ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី ទៅក្រុមហ៊ុន អ៊ិនធើ ឡូជីស្ទីក (ខេមបូឌា) ដែលកាន់កាប់ដោយ អ្នកឧកញ៉ា គិត ម៉េង
- បទបង្ហាញនៃសេចក្តីសម្រេចទី២: ការអនុម័តលើការបែងចែកភាគលាភ

ម្ចាស់ភាគហ៊ុនដែលនៅក្រៅប្រទេសមិនអាចចូលរួមក្នុងការប្រជុំបាន អាចមានអ្នកតំណាងណាម្នាក់នៅក្នុងប្រទេសដើម្បីចូលរួម និងបោះឆ្នោតលើសេចក្តីសម្រេច (ប្រសិនបើមាន) ក៏ដូចជាយើងនឹងចែករំលែកប្រព័ន្ធនៃការហៅជាវីដេអូទៅកាន់ពួកគេ។

PHNOM PENH SEZ PLC.
National Road No.4, Sangkat Kantuk, Khan Kambol, Phnom Penh, Cambodia.
t +855 (0)23 729 798 @ sales@ppsez.com
www.ppsez.com

PHNOM PENH
SPECIAL ECONOMIC ZONE
COMMITTED TO THE FUTURE

ភាគហ៊ុនិកដែលមានឈ្មោះក្នុងបញ្ជីឈ្មោះភាគហ៊ុនិកដែលបានរៀបចំនៅថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០២២ នឹងទទួលបានលិខិតអញ្ជើញ តាមរយៈសារអេឡិចត្រូនិក (info@tricoracambodia.com) ពីក្រុមហ៊ុន ត្រាយខ័រស៊ីយ្សូវីធី ស៊ីរីស ភីអិលស៊ី ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និង ភ្នាក់ងារទូទាត់ ជារៀងរាល់ ម៉ោងធ្វើការ ចាប់ពី ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០២២ ដល់ ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០២២។

បន្ទាប់ពីទទួលបានលិខិតអញ្ជើញតាមរយៈសេចក្តីជូនដំណឹងខាងលើ សូមភាគហ៊ុនិកមេត្តាអញ្ជើញឆ្លើយតបតាមរយៈសារអេឡិចត្រូនិដើម្បីកញ្ជាក់ពីការចូលរួមជាមួយក្រុមហ៊ុន ត្រាយខ័រ ស៊ីយ្សូវីធី ស៊ីរីស ភីអិលស៊ី ដោយភ្ជាប់មកជាមួយនូវ អត្តសញ្ញាណវិនិយោគិន និងអត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែន ចាប់ពី ថ្ងៃ១៧ ខែ មករា ឆ្នាំ ២០២២ ដល់ ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០២២។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកក្រុមហ៊ុន ត្រាយខ័រ ស៊ីយ្សូវីធី ស៊ីរីស ភីអិលស៊ី តាមអាសយដ្ឋាន និងលេខទំនាក់ទំនងដូចខាងក្រោម:

ក្រុមហ៊ុន ត្រាយខ័រ ស៊ីយ្សូវីធី ស៊ីរីស ភីអិលស៊ី

| | | |
|---|---|---|
| អាសយដ្ឋាន | ៖ | លេខ៨៧B ឧកញ៉ាជ្រុនយូហាក់ ផ្លូវលេខ២៩៤ សង្កាត់ បឹងកេងកង ខណ្ឌចំការមន រាជធានីភ្នំពេញ |
| ទូរស័ព្ទលេខ | ៖ | (៨៥៥) ២៣ ៩៨៧ ១០០ |
| ទូរសារលេខ | ៖ | (៨៥៥) ០១៥ ៨៨៨ ២៣៣ |
| អ៊ីម៉ែល | ៖ | info@tricoracambodia.com |
| គេហទំព័រ | ៖ | www.tricorcambodia.com |

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០២២

**ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី**

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី PHNOM PENH SEZ PLC. KINGDOM OF CAMBODIA